# ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៧៥

## ស្តីពី
## ការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២

## ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ១.-**

ត្រូវបានបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ដែលសរសេរជាអក្សរកាត់ថា **ប.ក.ទ.ក.** ជានីតិបុគ្គលនៃនីតិសាធារណៈ ដែលបានទទួលសិទ្ធិពីរាជរដ្ឋាភិបាល មានស្វ័យភាពក្នុងការងារត្រួតពិនិត្យ និងគ្រប់គ្រងខាងផ្លូវបច្ចេកទេសនិងរដ្ឋបាល លើការស្ថាបនា ការធ្វើប្រតិបត្តិការ ការផ្តល់ និងការប្រើប្រាស់បណ្តាញនិងសេវាទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានដូចមានចែងនៅក្នុងមាត្រា៣នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ២.-**

វាក្យសព្ទដែលប្រើក្នុងព្រះរាជក្រឹត្យនេះ មានន័យដូចខាងក្រោម៖

- **បញ្ញត្តិករទូរគមនាគមន៍កម្ពុជា (ប.ក.ទ.ក.)** សំដៅដល់អ្នករៀបចំបទប្បញ្ញត្តិនានានៃវិស័យទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា
- **កាតព្វកិច្ចសេវាសកល** សំដៅដល់កាតព្វកិច្ចបង្កើតសេវាដែលប្រជាពលរដ្ឋគ្រប់គ្នាមានលទ្ធភាពប្រើប្រាស់បាន
- **តារាងបែងចែកប្រេកង់** សំដៅដល់តារាងបែងចែករលកអាកាសវិទ្យុទាំងអស់ដែលបង្ហាញនូវការបែងចែកនិងការប្រើប្រាស់បង់នីមួយៗនៃប្រេកង់
- **ទីតាំងស្ថានីយទូរគមនាគមន៍** សំដៅដល់បរិក្ខារវិទ្យុនិងទូរស័ព្ទ ជាគ្រឿងឬប្រព័ន្ធដែលប្រើប្រាស់សម្រាប់ឆ្លើយឆ្លងព័ត៌មានឯកជនឬសាធារណៈ និងមានទីតាំងចល័តឬនៅនឹងមួយកន្លែង
- **ទូរគមនាគមន៍** សំដៅដល់ការផ្សាយ ការបញ្ជូន ឬការទទួលស៊ីញ៉ាល់ អក្សរ រូបភាព សំឡេង ឬព័ត៌មានគ្រប់ប្រភេទតាមមធ្យោបាយខ្សែកាប តាមអុបទិក តាមវិទ្យុអគ្គីសនី ឬតាមប្រព័ន្ធអេឡិចត្រូម៉ាញ៉េទិកផ្សេងៗទៀត
- **បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** សំដៅដល់សំណុំនៃទំនិញ សេវា សម្ភារៈដែលបានប្រើប្រាស់សម្រាប់ផលិត ទុកធ្វើប្រព្រឹត្តកម្ម ចែកចាយ និងផ្លាស់ប្តូរព័ត៌មាន
- **ប្លង់លេខទូរស័ព្ទនិងអាសយដ្ឋានអេឡិចត្រូនិក** សំដៅដល់ប្លង់ដែលពាក់ព័ន្ធនឹងការកំណត់លេខរៀងនិងអាសយដ្ឋានអេឡិចត្រូនិក
- **សេវាទូរគមនាគមន៍** សំដៅដល់សេវានៃប្រភេទទូរគមនាគមន៍ក្នុងនោះរួមមាន ទូរស័ព្ទ ទូរពុម្ព ទូរលេខ ទូរសារ អ៊ីនធឺណេត អ៊ីម៉ែល ទិន្នន័យ សេវាភ្ជាប់ដោយប្រព័ន្ធកុំព្យូទ័រ និងសេវាផ្សេងៗទៀត

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

- បណ្តាញទូរគមនាគមន៍ សំដៅដល់ប្រព័ន្ធដែលប្រើឬមានសមត្ថភាពក្នុងការប្រើប្រាស់សម្រាប់ផ្គត់ផ្គង់សេវាកម្មទូរគមនាគមន៍
- ផែនការប្រេកង់ស៍ជាតិ សំដៅដល់ផែនការដែលពាក់ព័ន្ធនឹងប្រេកង់ស៍ សម្រាប់ប្រើប្រាស់នៅប្រទេសកម្ពុជា
- ពិន័យអន្តរការណ៍ ប្រាក់ពិន័យដែល **ន.ក.ទ.ក.** មានសមត្ថកិច្ចតម្រូវឲ្យជនល្មើសបង់ស្របតាមទោសប្បញ្ញត្តិនៃច្បាប់ទូរគមនាគមន៍
- សម្ភារបរិក្ខារ សំដៅដល់ផ្នែកណាមួយនៃហេដ្ឋារចនាសម្ព័ន្ធរបស់បណ្តាញទូរគមនាគមន៍ រួមមាន ខ្សែកាប បន្ទប់បែងចែកបណ្តាញ សសរទូរស័ព្ទ បង្គោលអង់តែន រូងផ្លូវក្រោមដី បំពង់ទុយយោ អន្លង់ រណ្តៅ ជន្ទល់ ឬបរិក្ខារផ្សេងៗទៀត
- អាសយដ្ឋានអេឡិចត្រូនិក សំដៅដល់លេខឬអក្សរអេឡិចត្រូនិក សម្រាប់សម្គាល់អាសយដ្ឋានអ៊ីម៉ែល កុំព្យូទ័រ ឬឧបករណ៍ប្រហាក់ប្រហែល
- អាជ្ញាបណ្ណ សំដៅដល់អាជ្ញាបណ្ណបណ្តាញស្តង់ដា អាជ្ញាបណ្ណបណ្តាញ ដោយឡែក អាជ្ញាបណ្ណសេវាកម្មស្តង់ដា និងអាជ្ញាបណ្ណសេវាកម្មដោយឡែក
- អាជ្ញាបណ្ណប្រេកង់ស៍ សំដៅដល់អាជ្ញាបណ្ណផ្តល់ឲ្យបុគ្គលឬអង្គភាព ក្នុងការប្រើប្រាស់ប្រេកង់ស៍
- អាជ្ញាបណ្ណដោយឡែក សំដៅដល់អាជ្ញាបណ្ណចេញឲ្យអង្គភាពជាក់លាក់មួយ ដែលមានលក្ខខណ្ឌតម្រូវឲ្យអង្គភាពនោះបំពេញ
- អាជ្ញាបណ្ណបណ្តាញដោយឡែក សំដៅដល់អាជ្ញាបណ្ណ សម្រាប់ការសាងសង់ ម្ចាស់កម្មសិទ្ធិ និងការប្រតិបត្តិបណ្តាញទូរគមនាគមន៍ច្បាស់លាស់មួយ ចេញឲ្យអង្គភាពជាក់លាក់មួយ ដែលមានលក្ខខណ្ឌតម្រូវឲ្យអង្គភាពនោះបំពេញ
- អាជ្ញាបណ្ណសេវាកម្មដោយឡែក សំដៅដល់អាជ្ញាបណ្ណ សម្រាប់ផ្គត់ផ្គង់សេវាទូរគមនាគមន៍ច្បាស់លាស់មួយ ចេញឲ្យអង្គភាពជាក់លាក់មួយ ដែលមានលក្ខខណ្ឌតម្រូវឲ្យអង្គភាពនោះបំពេញ
- អ្នកទទួលអាជ្ញាបណ្ណ សំដៅដល់អ្នកកាន់អាជ្ញាបណ្ណក្នុងក្របខ័ណ្ឌព្រះរាជក្រឹត្យនេះ
- អ្នកទទួលអាជ្ញាបណ្ណបណ្តាញ សំដៅដល់អ្នកកាន់អាជ្ញាបណ្ណបណ្តាញស្តង់ដា ឬបណ្តាញដោយឡែក តាមបរិបទតម្រូវ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

- អ្នកទទួលអាជ្ញាបណ្ណសេវាកម្ម សំដៅដល់អ្នកកាន់អាជ្ញាបណ្ណសេវាកម្មស្តង់ដា ឬ ដោយឡែក តាមបរិបទតម្រូវ
- អាជ្ញាបណ្ណស្តង់ដា សំដៅដល់អាជ្ញាបណ្ណដែលផ្តល់ឲ្យដោយមានខ្លឹមសារនិងលក្ខខណ្ឌដូចគ្នាចំពោះអង្គភាពច្រើនសម្រាប់ប្រភេទដូចគ្នា
- អាជ្ញាបណ្ណសេវាកម្មស្តង់ដា សំដៅដល់អាជ្ញាបណ្ណសម្រាប់ការផ្គត់ផ្គង់សេវាទូរគមនាគមន៍ច្បាស់លាស់មួយ ដោយមានខ្លឹមសារនិងលក្ខខណ្ឌដូចគ្នា ចំពោះអង្គភាពច្រើន ដែលត្រូវបានទទួលអាជ្ញាបណ្ណ សម្រាប់ប្រភេទដូចគ្នានៃសេវាកម្ម
- អាជ្ញាបណ្ណបណ្តាញស្តង់ដា សំដៅដល់អាជ្ញាបណ្ណសម្រាប់ការសាងសង់ ម្ចាស់កម្មសិទ្ធិ និងការប្រតិបត្តិបណ្តាញទូរគមនាគមន៍ច្បាស់លាស់មួយ ដោយមានខ្លឹមសារនិងលក្ខខណ្ឌដូចគ្នា សម្រាប់ប្រភេទដូចគ្នានៃបណ្តាញ។

## ជំពូកទី២
## មុខងារនិងភារកិច្ចរបស់ ប.ក.ធ.ក.

**មាត្រា ៣.-**

**ប.ក.ធ.ក.** មានមុខងារនិងភារកិច្ចដូចតទៅ៖

ក- អនុវត្តគោលនយោបាយវិស័យទូរគមនាគមន៍ ដែលត្រូវបានកំណត់ឡើងដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ខ- ជំរុញឲ្យមានរចនាសម្ព័ន្ធវិស័យទូរគមនាគមន៍សមស្របតាមគោលនយោបាយវិស័យទូរគមនាគមន៍។

គ- ជំរុញនិងទ្រទ្រង់បរិស្ថានទីផ្សារទូរគមនាគមន៍ ដើម្បីឲ្យមានការប្រកួតប្រជែងប្រកបដោយយុត្តិធម៌និងប្រសិទ្ធភាពក្នុងវិស័យទូរគមនាគមន៍។

ឃ-ការពារផលប្រយោជន៍សាធារណជនក្នុងការទទួលសេវាកម្ម ដែលផ្តល់ដោយអ្នកទទួលអាជ្ញាបណ្ណ។

ង- រៀបចំនិងដាក់ឲ្យអនុវត្តបទប្បញ្ញត្តិសម្រាប់វិស័យទូរគមនាគមន៍រួមមាន៖

  - ចេញបទប្បញ្ញត្តិដើម្បីតម្រូវឲ្យអ្នកទទួលអាជ្ញាបណ្ណ ធ្វើការតភ្ជាប់បណ្តាញ និងអនុញ្ញាតឲ្យប្រតិបត្តិករដទៃប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម
  - តាមដាននិងគ្រប់គ្រងថ្លៃសេវាទូរគមនាគមន៍

- ចាត់តាំងនិងគ្រប់គ្រងកម្មវិធីកាតព្វកិច្ចនៃការប្រើប្រាស់សេវាសកល
- រៀបចំឲ្យមានស្តង់ដាសម្រាប់ប្រើប្រាស់ក្នុងវិស័យទូរគមនាគមន៍
- រៀបចំនិងគ្រប់គ្រងប្លង់លេខទូរស័ព្ទនិងអាសយដ្ឋានអេឡិចត្រូនិក
- រៀបចំនិងគ្រប់គ្រងប្រព័ន្ធនិងសេវាអ៊ីនធឺណេត
- រៀបចំនិងគ្រប់គ្រងប្លង់ជាតិប្រេកង់វិទ្យុ រួមទាំងការបែងចែកនិងចេញអាជ្ញាបណ្ណប្រេកង់ ដោយមានកិច្ចសហការជាមួយក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។
- កំណត់ខ្លឹមសារនិងលក្ខខណ្ឌនៃអាជ្ញាបណ្ណទូរគមនាគមន៍
- ចេញ កែសម្រួល ព្យួរ ផ្ទេរ និងដកហូតអាជ្ញាបណ្ណ
- តម្រូវឲ្យអ្នកទទួលអាជ្ញាបណ្ណទាំងអស់និងបុគ្គលដទៃទៀតគោរពតាមវិធាន និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ
- ធ្វើជាអ្នកសម្របសម្រួលវិវាទទាំងឡាយរវាងអ្នកទទួលអាជ្ញាបណ្ណនិងអ្នកទទួលអាជ្ញាបណ្ណ និងរវាងអ្នកទទួលអាជ្ញាបណ្ណនិងអ្នកប្រើប្រាស់សេវាទូរគមនាគមន៍។

ច- កំណត់បណ្តាញនិងសេវាទូរគមនាគមន៍ ដែលត្រូវមានអាជ្ញាបណ្ណស្តង់ដាឬអាជ្ញាបណ្ណដោយឡែកនិងកំណត់មូលដ្ឋានលក្ខណសម្បត្តិសម្រាប់ចេញអាជ្ញាបណ្ណនេះ។

ឆ- ផ្តល់សេចក្តីណែនាំនិងជួយសម្រួលដល់អ្នកប្រកបរបរខាងវិស័យទូរគមនាគមន៍។

ជ- រៀបចំរបាយការណ៍និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អំពីបញ្ហាពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍។

ឈ- ផ្តល់របាយការណ៍ប្រតិបត្តិការនិងហិរញ្ញវត្ថុពាក់ព័ន្ធនឹងសកម្មភាពរបស់ប្រតិបត្តិករទូរគមនាគមន៍ជាទៀងរាល់ឆ្នាំ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ញ- លើកសំណើសុំកំណត់កម្រៃអាជ្ញាបណ្ណសម្រាប់អ្នកទទួលអាជ្ញាបណ្ណគ្រប់ប្រភេទ។

ដ- ចេញបទប្បញ្ញត្តិនិងបទបញ្ជាសមស្រប ព្រមទាំងបញ្ជាផ្អាកជាបណ្តោះអាសន្នឬជាស្ថាពរ ចំពោះប្រតិបត្តិការបណ្តាញនិងការផ្តល់សេវាទូរគមនាគមន៍។

ពិន័យអន្តរការណ៍ ផ្អាកការផ្តល់ និងប្រើប្រាស់សេវាកម្មទូរគមនាគមន៍ ព្យួរឬដកហូតអាជ្ញាបណ្ណ ចំពោះការរំលោភលើច្បាប់និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់បញ្ញត្តិករ

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★

ទូរគមនាគមន៍កម្ពុជា។

ឌ- ផ្សព្វផ្សាយបទប្បញ្ញត្តិ សេចក្តីណែនាំ លិខិតបទដ្ឋាន និងឯកសារដទៃទៀត ដែលខ្លួនបានរៀបចំឡើង។

ឍ-បណ្តុះបណ្តាលនិងអភិវឌ្ឍបុគ្គលិករបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

ណ- ត្រួតពិនិត្យទីតាំងស្ថានីយទូរគមនាគមន៍។

ត- ជំរុញឲ្យមានការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យាទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន ឧស្សាហកម្មទូរគមនាគមន៍។

ថ- ចេញបទប្បញ្ញត្តិស្តីពីការរៀបចំរចនាសម្ព័ន្ធ ការគ្រប់គ្រងបុគ្គលិក ថវិកាហិរញ្ញវត្ថុ កម្មសិទ្ធិនិងមុខងារដទៃទៀតនៃទីស្នាក់ការបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

ទ- ផ្តល់ការយល់ព្រមលើថវិកាសម្រាប់ទីស្នាក់ការបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

ធ- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាលនិងបទប្បញ្ញត្តិច្បាប់ជាធរមាន។

## ជំពូកទី៣
## សមាជិកភាព ប.ក.ទ.ក.

**មាត្រា ៤.-**

**ប.ក.ទ.ក.**មានសមាសភាពចំនួន៣(បី)រូប ដែលក្នុងនោះមានប្រធាន១(មួយ)រូបនិងសមាជិក២(ពីរ)រូប។

ប្រធាននិងសមាជិកត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទៅនាយករដ្ឋមន្ត្រី មានអាណត្តិ៣(បី)ឆ្នាំ ហើយត្រូវបញ្ចប់ក្នុងពេលខុសគ្នា លើកលែងតែក្នុងអាណត្តិដំបូងដូចមានចែងក្នុងមាត្រា២៣នៃព្រះរាជក្រឹត្យនេះ។

ប្រធានមានឋានៈស្មើរដ្ឋលេខាធិការ និងសមាជិកមានឋានៈស្មើអនុរដ្ឋលេខាធិការ។

ប្រធាននិងសមាជិក **ប.ក.ទ.ក.** អាចត្រូវបានតែងតាំងអាណត្តិបន្តទៀតបាន។

**មាត្រា ៥.-**

បុគ្គលដែលអាចត្រូវបានជ្រើសរើសជាប្រធាននិងសមាជិក **ប.ក.ទ.ក.**បានត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

- មានសញ្ញាបត្រចាប់ពីកម្រិតឧត្តមសិក្សាឡើងទៅក្នុងផ្នែកវិស្វកម្មទូរគមនាគមន៍ ឬនីតិសាស្ត្រឬសេដ្ឋកិច្ចឬគណនេយ្យឬហិរញ្ញវត្ថុ
- មានបទពិសោធការងារយ៉ាងតិច៥(ប្រាំ)ឆ្នាំពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- មានសមត្ថភាពការងារ មានភាពស្អាតស្អំ និងមានគុណធម៌
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយឬធ្លាប់ទទួលការផ្តន្ទាទោសដូចចែងខាងលើ តែត្រូវបានទទួលនីតិសម្បទារួចហើយ។

**មាត្រា ៦.-**

ក្នុងអាណត្តិរបស់ខ្លួន ប្រធាននិងសមាជិក **ន.ក.ទ.ក.** មានវិសមិតភាពជាមួយមុខងារជាមន្ត្រីរាជការ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឬជាទីប្រឹក្សាជំនួយការនៃក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

សាមីជនដែលកំពុងបម្រើការងារដូចមានចែងក្នុងកថាខណ្ឌខាងលើ ហើយត្រូវបានទទួលការតែងតាំងជាប្រធានឬជាសមាជិក **ន.ក.ទ.ក.** ត្រូវធ្វើលិខិតសុំលាលែងចេញពីមុខតំណែងឬព្យួរការងារជាបណ្តោះអាសន្នសម្រាប់រយៈពេលបំពេញការងារក្នុងអាណត្តិរបស់ខ្លួន។

**មាត្រា ៧.-**

ប្រធាននិងសមាជិក **ន.ក.ទ.ក.** ត្រូវធ្វើការពេញម៉ោងនៅ **ន.ក.ទ.ក.** និងមិនត្រូវធ្វើការ ឬយល់ព្រមទទួលកម្រៃពីសកម្មភាពផ្សេងៗក្នុងវិស័យពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនឡើយ។

**មាត្រា ៨.-**

ប្រធាននិងសមាជិកព្រមទាំងមន្ត្រីទាំងអស់របស់ **ន.ក.ទ.ក.** មិនអាចមានភាគហ៊ុនដោយផ្ទាល់ឬមានផលប្រយោជន៍សេដ្ឋកិច្ចឬមានមុខនាទីជាមួយអ្នកទទួលអាជ្ញាបណ្ណឬអ្នកសុំអាជ្ញាបណ្ណបានឡើយ ប៉ុន្តែអាចធ្វើជាអ្នកជាវឬអ្នកប្រើប្រាស់សេវារបស់អ្នកទទួលអាជ្ញាបណ្ណ។

ក្នុងអាណត្តិរបស់ខ្លួន ប្រធាននិងសមាជិកទាំងអស់របស់ **ន.ក.ទ.ក.** ព្រមទាំងសហព័ទ្ធឬកូនមិនអាចចូលបម្រើការងារឬទទួលតំណែងណាមួយជាទីប្រឹក្សាឬជាអ្នកពិគ្រោះការងារ និងមិនអាចមានភាគហ៊ុនឬបណ្ណវតនាគារឬមានផលប្រយោជន៍ជាប្រាក់ជាមួយអ្នកកាន់អាជ្ញាបណ្ណឬជាមួយបុគ្គលដទៃទៀតដែលមានទំនាក់ទំនងក្នុងការផ្តល់សេវាកម្មទូរគមនាគមន៍ឬដំណើរការដែលពាក់ព័ន្ធណាមួយបានឡើយ។

**មាត្រា ៩.-**

តំណែងប្រធានឬសមាជិក **ន.ក.ទ.ក.** ត្រូវចាត់ទុកថានៅទំនេរ នៅពេលដែលសាមីជនៈ

- ទទួលមរណភាព
- លាលែងពីមុខតំណែង

- បាត់បង់សមត្ថភាពការងារខាងបញ្ញាស្មារតីនិងកាយសម្បទា
- មានកំហុសធ្ងន់ធ្ងរនិងខ្វះការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ខ្លួន
- ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋ។

**មាត្រា ១០.-**

ក្នុងករណីដែលតំណែងប្រធានឬសមាជិក **ប.ភ.ឆ.ភ.** នៅទំនេរមុនចប់អាណត្តិ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរៀបចំសមាសភាពថ្មីស្នើទៅនាយករដ្ឋមន្ត្រី ដើម្បីស្នើសុំតែងតាំងបំពេញអាណត្តិរបស់ប្រធានឬសមាជិកដែលនៅទំនេរនោះ។

**មាត្រា ១១.-**

ក្នុងរយៈពេល២(ពីរ)ឆ្នាំចាប់ពីពេលបញ្ចប់អាណត្តិឬលាលែងពីមុខតំណែងរបស់ខ្លួន ប្រធាននិងសមាជិក **ប.ភ.ឆ.ភ.** មិនត្រូវបានអនុញ្ញាតឲ្យចូលបម្រើការងារ ឬមានទំនាក់ទំនងជាទីប្រឹក្សា ឬជាអ្នកជំនាញការ ឬជាអ្នកពិគ្រោះយោបល់ជូនអ្នកទទួលអាជ្ញាបណ្ណទូរគមនាគមន៍ណាមួយបានឡើយ។

**មាត្រា ១២.-**

ប្រាក់បៀវត្សរ៍ ប្រាក់បំណាច់ និងអត្ថប្រយោជន៍ផ្សេងៗទៀត របស់ប្រធាននិងសមាជិក **ប.ភ.ឆ.ភ.** ត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃ ប.ភ.ឆ.ភ.

**មាត្រា ១៣.-**

ប្រធាននិងសមាជិក **ប.ភ.ឆ.ភ.** អាចរួមប្រជុំគ្នាបានតាមតម្រូវការចាំបាច់ ដោយមានការស្នើពីប្រធានឬសមាជិកទាំង២(ពីរ)រូប។

ការប្រជុំនេះត្រូវធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធាន **ប.ភ.ឆ.ភ.**។ ប្រធាននិងសមាជិកត្រូវមានសំឡេងក្នុងការបោះឆ្នោតលើរាល់បញ្ហាដែលតម្រូវឲ្យមានការអនុម័តពី **ប.ភ.ឆ.ភ.**។ ការអនុម័តនេះត្រូវផ្អែកលើសំឡេងភាគច្រើន ក្នុងករណីសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។ ការអនុម័តរបស់ **ប.ភ.ឆ.ភ.** យកជាការបានលុះត្រាតែមានវត្តមានប្រធានឬប្រធានស្តីទីដែលត្រូវបានចាត់តាំងដោយប្រធាននិងសមាជិក១(មួយ)រូបយ៉ាងតិច។

ប្រធាននិងសមាជិកទាំងអស់ត្រូវបានទទួលនូវសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទ ទីកន្លែងនិងកម្មវត្ថុនៃកិច្ចប្រជុំ។

សេចក្តីសម្រេចរបស់ **ម.ភ.ឆ.ភ.** ត្រូវកត់ត្រាទុកក្នុងរបាយការណ៍នៃការប្រជុំ ដោយមានចុះហត្ថលេខារបស់ប្រធាន សមាជិកទាំងអស់ដែលបានចូលរួមប្រជុំ និងលេខាធិការនៃអង្គប្រជុំដែលត្រូវចាត់តាំងដោយប្រធាន។

**មាត្រា ១៤.–**

ដើម្បីធ្វើសេចក្តីសម្រេចណាមួយ ប្រធាននិងសមាជិកនៃ **ម.ភ.ឆ.ភ.** ត្រូវធ្វើការពិចារណាឲ្យបានហ្មត់ចត់និងត្រឹមត្រូវលើបញ្ហាទាំងអស់ដែលពាក់ព័ន្ធឲ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យទូរគមនាគមន៍ ។

រាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនេះត្រូវថែងលម្អិតក្នុងសេចក្តីប្រកាសជាសាធារណៈមួយធ្វើដោយ **ម.ភ.ឆ.ភ.** នៅមុនពេលធ្វើសេចក្តីសម្រេចលើបទប្បញ្ញត្តិណាមួយនោះ។

**មាត្រា ១៥.–**

មុនពេលប្រកាសឲ្យប្រើបទបញ្ជាទូទៅ វិធានឬបទប្បញ្ញត្តិណាមួយ **ម.ភ.ឆ.ភ.** ត្រូវជូនដំណឹងពីខ្លឹមសារនិងលក្ខខណ្ឌ ហើយត្រូវផ្តល់ឱកាសឲ្យនីតិបុគ្គលដែលពាក់ព័ន្ធនិងសាធារណជនបង្ហាញភស្តុតាងនិងបញ្ចេញមតិយោបល់។ **ម.ភ.ឆ.ភ.** ត្រូវជូនដំណឹងសមស្របដល់នីតិបុគ្គលឬជននោះអំពីពេលវេលានិងទីកន្លែងសម្រាប់នីតិបុគ្គលនោះមានឱកាសផ្តល់ភស្តុតាងនិងបញ្ចេញមតិយោបល់។ រាល់បទបញ្ជា វិធាន និងបទប្បញ្ញត្តិទាំងនោះត្រូវផ្តល់ជូនដល់សាធារណជនមុនពេលដែល **ម.ភ.ឆ.ភ.** ធ្វើការសន្និដ្ឋានចេញបទបញ្ជាឬសេចក្តីសម្រេចពាក់ព័ន្ធនីតិបុគ្គលឬជនណាមួយ ។

**មាត្រា ១៦.–**

បន្ទាប់ពី **ម.ភ.ឆ.ភ.** ចេញសេចក្តីសម្រេចជាចុងក្រោយ នីតិបុគ្គលឬជនពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា។ ការប្តឹងតវ៉ានេះត្រូវអនុវត្តក្នុងរយៈពេល៩០(កៅសិប)ថ្ងៃបន្ទាប់ពីចេញសេចក្តីសម្រេចខាងលើ។

**មាត្រា ១៧.–**

**ម.ភ.ឆ.ភ.** មានលេខាធិការដ្ឋានមួយជាសេនាធិការ។ លេខាធិការដ្ឋាននៃ **ម.ភ.ឆ.ភ.** ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើអគ្គនាយកនិងអនុប្រធានមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការតាមការចាំបាច់។

ប្រធានត្រូវតែងតាំងដោយព្រះរាជក្រឹត្យនិងអនុប្រធានត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទៅនាយករដ្ឋមន្ត្រី។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **ម.ភ.ឆ.ភ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៨.-**

**ប.ភ.ឆ.ក.** មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ក្នុងករណីចាំបាច់ **ប.ភ.ឆ.ក.** អាចជ្រើសរើសមន្ត្រីជាប់កិច្ចសន្យានិងជួលអ្នកឯកទេសផ្សេងទៀត តាមតម្រូវការចាំបាច់សម្រាប់អនុវត្តភារកិច្ចរបស់ខ្លួនបាន។ មន្ត្រីជាប់កិច្ចសន្យានិងអ្នកឯកទេសរបស់ **ប.ភ.ឆ.ក.** ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

ប្រាក់បៀវត្សរ៍និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីជាប់កិច្ចសន្យានិងអ្នកឯកទេសរបស់ **ប.ភ.ឆ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ប.ភ.ឆ.ក.**។

**មាត្រា ១៩.-**

**ប.ភ.ឆ.ក.** មាននិមិត្តសញ្ញានិងត្រាដោយឡែករបស់ខ្លួន។

## ជំពូកទី៥
## ធនធាននិងថវិការបស់ ប.ភ.ឆ.ក.

**មាត្រា ២០.-**

**ប.ភ.ឆ.ក.** មានថវិកាស្វយ័តមួយសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ ថវិកានេះមានជាអាទិ៍ៈ

- ដើមទុនដែលរដ្ឋផ្តល់ឲ្យ(តុល្យការដំបូងនៅពេលបង្កើត)
- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យបន្ថែម
- កម្រៃដែលអ្នកសុំអាជ្ញាបណ្ណនិងអ្នកទទួលអាជ្ញាបណ្ណត្រូវបង់ព្រមទាំងកម្រៃផ្សេងៗ តាមការកំណត់របស់ **ប.ភ.ឆ.ក.**
- ប្រាក់បានមកពីប្រភពជំនួយផ្សេងៗ។

ថវិការបស់ **ប.ភ.ឆ.ក.** ត្រូវតម្កល់ទុកក្នុងគណនីមួយនៅធនាគាររបស់រដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា។ មានតែ **ប.ភ.ឆ.ក.** ទេ ដែលមានសិទ្ធិប្រើប្រាស់ថវិកានេះ។

**មាត្រា ២១.-**

**ប.ភ.ឆ.ក.** ត្រូវបង្កើតគម្រោងថវិកាសម្រាប់កិច្ចប្រតិបត្តិការនៃការិយបរិច្ឆេទនីមួយៗដែលមានកំណត់ចំណូលនិងចំណាយរបស់ **ប.ភ.ឆ.ក.**។ គម្រោងថវិកាត្រូវកំណត់ឲ្យបានច្បាស់លាស់នូវកម្រៃអាជ្ញាបណ្ណនិងកម្រៃផ្សេងៗ សម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗរួមទាំងវិធីគណនាកម្រៃអាជ្ញាបណ្ណនិងកម្រៃផ្សេងៗព្រមទាំងបៀវត្សរ៍និងប្រាក់ចំណាយផ្សេងទៀតដែលត្រូវទូទាត់ជូន ប្រធាន សមាជិក និងមន្ត្រីរបស់ **ប.ភ.ឆ.ក.** ។

**ប.ភ.ឆ.ក.** ត្រូវដាក់គម្រោងថវិកានេះជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចតាមសំណើរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កម្រៃអាជ្ញាបណ្ណនិងកម្រៃផ្សេងៗត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ក្នុងករណីមានសំណល់ថវិកានៅដំណាច់ឆ្នាំណាមួយ **ម.ភ.ឆ.ភ.** ត្រូវផ្ទេរសំណល់ថវិកានោះទៅប្រើប្រាស់សម្រាប់គម្រោងថវិកាឆ្នាំបន្ទាប់ទៀតស្របតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ចំពោះកង្វះថវិកាដូចមានចែងក្នុងកថាខណ្ឌខាងលើ **ម.ភ.ឆ.ភ.** ត្រូវកែសម្រួលកម្រៃអាជ្ញាបណ្ណនិង/ឬកម្រៃផ្សេងទៀតឡើងវិញសម្រាប់គម្រោងថវិកាឆ្នាំបន្ទាប់។

ក្នុងករណីកែសម្រួលកម្រៃអាជ្ញាបណ្ណនិង/ឬកម្រៃផ្សេងទៀតរហូតដល់កម្រិតអតិបរមារួចហើយ ប៉ុន្តែនៅតែពុំអាចទ្រទ្រង់កិច្ចប្រតិបត្តិការរបស់ខ្លួន **ម.ភ.ឆ.ភ.** ត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេចកម្រិតអតិបរមានៃកម្រៃអាជ្ញាបណ្ណនិង/ឬកម្រៃផ្សេងៗជាថ្មីឡើងវិញ។

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យរបស់ **ម.ភ.ឆ.ភ.** ត្រូវអនុវត្តតាមប្រព័ន្ធគណនេយ្យសាធារណៈនិងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**មាត្រា ២២.-**

**ម.ភ.ឆ.ភ.**ត្រូវរៀបចំរបាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំឲ្យបានយ៉ាងយូរបំផុត៣០(សាមសិប)ថ្ងៃក្រោយឆ្នាំការិយបរិច្ឆេទ។

របាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំរួមទាំងសៀវភៅគណនីរបស់ **ម.ភ.ឆ.ភ.** និងកំណត់ហេតុពាក់ព័ន្ធត្រូវបានធ្វើសវនកម្ម។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីធ្វើសវនកម្មរួចរបាយការណ៍ទាំងអស់នោះត្រូវដាក់ជូនទៅនាយករដ្ឋមន្ត្រីតាមរយៈក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយ **ម.ភ.ឆ.ភ.** ដើម្បីពិនិត្យ សម្រេច និងត្រូវផ្សព្វផ្សាយជាសាធារណៈ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ២៣.-**

សម្រាប់អាណត្តិដំបូង បន្ទាប់ពីព្រះរាជក្រឹត្យនេះចូលជាធរមានក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវស្នើសុំទៅនាយករដ្ឋមន្ត្រី ដើម្បីរៀបចំការតែងតាំងប្រធាន **ម.ភ.ឆ.ភ.** មួយរូបសម្រាប់អាណត្តិ៣(បី)ឆ្នាំនិងសមាជិក២(ពីរ)រូបទៀតដែលសមាជិកទីមួយមានអាណត្តិ២(ពីរ)ឆ្នាំនិងសមាជិកទីពីរមានអាណត្តិ១(មួយ)ឆ្នាំ ព្រមទាំងប្រធានលេខាធិការដ្ឋាននៃ **ម.ភ.ឆ.ភ.** មួយរូប។

**មាត្រា ២៤.-**

ក្នុងពេលចាប់ផ្តើមដំណើរការការងាររបស់ខ្លួន **ម.ភ.ឆ.ភ.** ត្រូវបានផ្តល់មូលនិធិដំបូងពីរាជរដ្ឋាភិបាល។ មូលនិធិនេះ ត្រូវដាក់តម្កល់ក្នុងគណនីមួយដោយឡែកនៅក្នុងធនាគាររដ្ឋនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ការប្រើប្រាស់របស់ **ម.ភ.ឆ.ភ.**។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២៥.-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវផ្ទេរតួនាទីនិងភារកិច្ចទៅ **ប.ក.ធ.ក.** ជាបណ្ដើរៗស្របតាមព្រះរាជក្រឹត្យនេះ នៅពេល **ប.ក.ធ.ក.** ចាប់ផ្ដើមដំណើរការការងាររបស់ខ្លួន។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបន្តការប្រមូលចំណូលនិងបំណុលដូចមានចែងក្នុងមាត្រា២០នៃព្រះរាជក្រឹត្យនេះរហូតដល់ **ប.ក.ធ.ក.** ចាប់ផ្ដើមដំណើរការងាររបស់ខ្លួន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ លើកលែងតែព្រះរាជក្រឹត្យលេខ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០០ ស្ដីពីការបង្កើតអាជ្ញាធរជាតិមួយសម្រាប់ទទួលបន្ទុករៀបចំនិងអភិវឌ្ឍគោលនយោបាយសម្រាប់រយៈពេលខ្លី មធ្យម និងវែង ដើម្បីជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាហៅថា អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (National Information Communications Technology Development Authority) ត្រូវទុកជាធរមាន។

**មាត្រា ២៧.-**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១២

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នសរកត-០៣១២-១៤០

**បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ**

**សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ១៧៤០.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ មីនា ឆ្នាំ២០១២

**អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល**

១២/១២

**សយ សុខា**

14/12